**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

MINISTRY OF ECONOMY AND FINANCE

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ......៦៩៦.....សហវ.ប្រក

រាជធានីភ្នំពេញ,ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០០៥

# ប្រកាស
## ស្តីពី
## ការបង្កើតគណៈកម្មការបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ ប្រចាំក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## ទេសរដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស.រកត/០៧០៤/០០១ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានាដំណើរការជាប្រក្រតី នៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២នស.៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខនស/រកម/០៨០១/០៤ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញអនុក្រឹត្យលេខ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែមករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃក្រសួងសេដ្ឋកិច្ច និ ងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ៧៨ អនក្រ.បក ចុះថ្ងៃទី ១៨ ខែវិច្ឆិកា ឆ្នាំ ២០០៤ ស្តីពីការបំពេញបន្ថែម និងកែសំរួលនាយកដ្ឋានមួយចំនួន នៃក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញបទបញ្ជាលេខ ៣០ បប ចុះថ្ងៃទី ២៥ ខែធ្នូ ឆ្នាំ ១៩៩៧ របស់រាជរដ្ឋាភិបាល ស្តីពីការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ
- បានឃើញសារាចរណែនាំលេខ០១៦ សរ.សហវ ចុះថ្ងៃទី ១៩ ខែវិច្ឆិកា ឆ្នាំ ១៩៩៩ ស្តីពីថែរក្សាទ្រព្យសម្បត្តិរដ្ឋ និង ចំណារសម្តេចនាយករដ្ឋមន្ត្រី ចុះថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ១៩៩៩
- បានឃើញបទបញ្ជាលេខ ០២ បប ចុះថ្ងៃទី ១៣ ខែមិថុនា ឆ្នាំ ២០០៥ របស់រាជរដ្ឋាភិបាល
- បានឃើញចំណាររបស់ឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ចុះថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០០៤
- យោងការផ្លាស់ប្តូរភារកិច្ចមន្ត្រី ចំនួន០២រូប មន្ត្រីចូលនិវត្តន៍ចំនួន ០២រូប នៃប្រកាសលេខ ៩១០ សហវ ចុះថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០០១ និងបំពេញបន្ថែមមន្ត្រីជាសមាជិកគណៈកម្មការ ចំនួន ០២រូប
- យោងការងារចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សំរេច

**ប្រការ១** : បង្កើតគណៈកម្មការបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋប្រចាំក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដែលមានសមាសភាពដូចខាងក្រោម :

| | | |
|---|---|---|
| ១-ឯកឧត្តម ញាណ ឡេង | អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ | ប្រធាន |
| ២-លោក ឃុត សាខន | ប្រធាននាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ | អនុប្រធាន |
| ៣- លោក នេត មុន្នី | ប្រធាននាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ | អនុប្រធាន |
| ៤- លោក វង្ស ជាវ | ប្រធានការិយាល័យនីតិកម្មហិរញ្ញវត្ថុ នៃនាយកដ្ឋាននីតិកម្ម | សមាជិកអចិន្ត្រៃយ៍ ✓ |
| ៥- លោក លីវ ប៊ុនហៃ | ប្រធាននាយកដ្ឋានហិរញ្ញវត្ថុមូលដ្ឋាន | សមាជិក |
| ៦- លោក ឡាយ ឫទ្ធី | នាយករងទីចាត់ការគយ និង រដ្ឋាករ | សមាជិក |
| ៧- លោក ម៉ី រិន | អនុប្រធានរតនាគារជាតិ | សមាជិក |
| ៨- លោក វង្ស វិជាវុឌ្ឍ | អនុប្រធាននាយកដ្ឋានលទ្ធកម្មសាធារណៈ | សមាជិក |
| ៩- លោក ចាន់ ស៊ី | អនុប្រធាននាយកដ្ឋានពន្ធដារ | សមាជិក |
| ១០- លោក គុយ សាវុធ | អនុប្រធាននាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ | សមាជិក |
| ១១-លោក មាស ចាន់ដេត | ប្រធានការិយាល័យគណនេយ្យនៃនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ | សមាជិក |
| ១២-លោក ហែម ស៊ីវន | ប្រធានការិយាល័យសារពើភ័ណ្ឌ នៃនាយកដ្ឋាទ្រព្យសម្បត្តិរដ្ឋ | សមាជិក |
| ១៣-លោក ម៉ុក ស៊ីជា | ប្រធានការិយាល័យត្រួតពិនិត្យ នៃនាយកដ្ឋានបុគ្គលិក | សមាជិក |
| ១៤-លោក ម៉ែន ណារុន | អនុប្រធានការិយាល័យសារពើភ័ណ្ឌ នៃនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ | សមាជិក |
| ១៥- លោក ហេង សុខ័ណ្ឌ | មន្ត្រីនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ | សមាជិក |
| ១៦- លោក ហ៊ុន ពិសិដ្ឋ | មន្ត្រីនាយកដ្ឋាននីតិកម្ម | លេខាធិការ និងជាការីកុំព្យូទ័រ ✓ |

**ប្រការ២** : គណៈកម្មការនេះមានភារកិច្ច :

- ត្រួតពិនិត្យ ផ្ទៀងផ្ទាត់ប្រចាំឆ្នាំនូវបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ របស់អង្គភាពនៅថ្នាក់កណ្ដាលចំណុះទីស្តីការក្រសួង និងមន្ទីរ-អង្គភាពជំនាញនៅតាមខេត្ត-ក្រុង ក្រោមឱវាទក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដែលគ្រប់គ្រង និងប្រើប្រាស់ទ្រព្យសម្បត្តិរដ្ឋ ទោះបីធ្វើអាជីវកម្ម ឬ ប្រើប្រាស់ជាផលប្រយោជន៍រួមក៏ដោយព្រមទាំងកត់ត្រាឱ្យបានច្បាស់លាស់អំពីចំនួនកើន និង ចំនួនថយ ដោយប្រការផ្សេងៗដូចជា ដីធ្លី អគារ សម្ភារៈបរិក្ខារ....ដែលអាជ្ញាធរដែនដី អង្គការអន្តរជាតិនានា សប្បុរសជនជាតិ និង អន្តរជាតិប្រគល់ឱ្យកន្លងមក លទ្ធផលនៃការប្រើប្រាស់ឥណទានសំរាប់ទិញដី ការកសាងថ្មី ជួសជុលអគារ សម្ភារៈបរិក្ខារ បច្ចេកទេសឧស្សាហកម្ម ការប្រើប្រាស់ឥណទានជំពូក ១១ កថាខ័ណ្ឌ២ និង ការប្រើប្រាស់ប្រាក់រង្វាន់ ។ ល ។ ដើម្បីកត់ត្រាចូលក្នុងបញ្ជីសារពើភ័ណ្ឌជាទ្រព្យសម្បត្តិរដ្ឋ ។
- រាយការណ៍ជូនឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ស្តីពីលទ្ធផលការត្រួតពិនិត្យផ្ទៀងផ្ទាត់ធ្វើបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ អំពីចំនួនកើន និង ចំនួនថយទ្រព្យសម្បត្តិរដ្ឋ របស់អង្គភាពនៅថ្នាក់កណ្ដាលចំណុះទីស្តីការក្រសួង និង មន្ទីរ-អង្គភាព ជំនាញនៅតាមខេត្ត-ក្រុង ព្រមទាំងលើកសំណើជូនឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដើម្បីពិនិត្យ និង សំរេច :

+ អំពីករណីដីធ្លី ដែលទុកចោលទំនេរ និង ធ្វើការបែងចែកដីជូនអង្គភាពជំនាញហិរញ្ញវត្ថុ ខេត្ត-ក្រុង ដែលគ្មានទីតាំងរដ្ឋបាល ដើម្បីជៀសវាងប្រការចំណាយឥណទានរបស់ក្រសួងក្នុងការទិញដីថ្មីឡើយ ។

+ អគារ យានយន្ត គ្រឿងចក្រ និងសម្ភារៈ សង្ហារឹម ដែលអស់តម្លៃក្នុងការប្រើប្រាស់ត្រូវស្នើសុំគោលការណ៍ជំរះចេញពីបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ ។

- ក្នុងករណីចាំបាច់ ឬ មានវិវាទកម្មផ្សេងៗ គណៈកម្មការនេះត្រូវធ្វើអង្កេតវាយតម្លៃទ្រព្យសម្បត្តិរដ្ឋ គ្រប់អង្គភាពនៅថ្នាក់ កណ្ដាលចំណុះទីស្ដីការក្រសួង និង មន្ទីរ-អង្គភាពជំនាញនៅតាមខេត្ត-ក្រុង ជាបន្ទាន់ដោយមិនបាច់ជូនដំណឹងជាមុនឡើយ ដើម្បីទប់ស្កាត់រាល់បាតុភាពរំលោភបំពារបំពានយកទ្រព្យសម្បត្តិរដ្ឋ ។

ប្រការ៣ : រាល់លិខិតបទដ្ឋានទាំងឡាយណា ដែលផ្ទុយនិងប្រកាសនេះត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ៤ : ឯកឧត្តមអគ្គលេខាធិការ នាយកខុទ្ទកាល័យ នាយកដ្ឋានបុគ្គលិក នាយកដ្ឋានរដ្ឋបាល និង ហិរញ្ញវត្ថុ នាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ នាយកដ្ឋាននីតិកម្ម នាយកដ្ឋានហិរញ្ញវត្ថុមូលដ្ឋាន ទីចាត់ការគយ និង រដ្ឋាករ រតនាគារជាតិ នាយកដ្ឋានពន្ធដារ មន្ទីរសេដ្ឋកិច្ច និង ហិរញ្ញវត្ថុគ្រប់ខេត្ត-ក្រុង អង្គភាពពាក់ព័ន្ធ ព្រមទាំងអស់លោកដូចមានចែងក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តតាមប្រកាស នេះឱ្យមានប្រសិទ្ធិភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

គាត ឈន់

ចំលងជូន :
ទីស្ដីការគណៈរដ្ឋមន្ត្រី
- គ្រប់សាលាខេត្ត-ក្រុង
"ដើម្បីជូនជ្រាប"
- គ្រប់នាយកដ្ឋាន និងអង្គភាពចំណុះទីស្ដីការក្រសួង
- ដូចប្រការ៤
"ដើម្បីអនុវត្ត"
- ឯកសារ - កាលប្បវត្តិ